**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ នៅចំណុចភូមិព្រងើយ ឃុំគ្មៀងរាយ ស្រុកកញ្ជៀច ខេត្តព្រៃវែង ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលដំណឹងថា មានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ ដោយរថយន្តដឹកកម្មករនិយោជិតបើកស្របទិសគ្នាជាមួយនឹងរថយន្តដឹកដី ស្រាប់តែមកដល់ចំណុចកើតហេតុ រថយន្តដឹកដីបានបុករថយន្តដឹកកម្មករនិយោជិតពីក្រោយ កាលពីវេលា ម៉ោង ០៦ និង ១៥ នាទីព្រឹក ថ្ងៃអង្គារ ១២រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ នៅចំណុចមុខសាលាឃុំគ្មៀងរាយ ភូមិព្រងើយ ឃុំគ្មៀងរាយ ស្រុកកញ្ជៀច ខេត្តព្រៃវែង។ ដែលបណ្តាលឱ្យកម្មការិនីរងរបួសសរុបចំនួន ៣នាក់ (រងរបួសស្រាលទាំងអស់) ក្នុងចំណោមកម្មករនិយោជិតចំនួន ៦០នាក់។ ជនរងគ្រោះទាំងអស់បានទទួលការជួយសង្គ្រោះពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយយកចិត្តទុកដាក់បំផុត។ គិតត្រឹមម៉ោង ១០ និង ៣០ នាទីព្រឹក នៅថ្ងៃខែឆ្នាំដដែលនេះ កម្មករនិយោជិតចំនួន ៣នាក់ (ស្រី) កំពុងសម្រាកព្យាបាលនៅគ្លីនិកបន្ទប់ពិគ្រោះព្យាបាលទូទៅស្វាយរមៀត ស្ថិតនៅទីរួមស្រុកកញ្ជៀច ខេត្តព្រៃវែង។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមចូលរួមចែករំលែក និងអាណិតស្រលាញ់ជាទីបំផុត ជាមួយក្រុមគ្រួសារ និងញាតិមិត្តទាំងអស់នៃជនរងគ្រោះ ហើយសូមជូនពរដល់អ្នករងរបួសទាំងអស់ឆាប់បានជាសះស្បើយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តជួយដោះស្រាយទុក្ខលំបាករបស់បងប្អូនកម្មការិនី និងក្រុមគ្រួសារទៅតាមគោលការណ៍នៃបេឡាជាតិរបបសន្តិសុខសង្គម៕

ថ្ងៃអង្គារ ១២រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩